

# ការពិនិត្យស្បូនរបៀបផែលវិក

(Pelvic Exam)

# និងរបៀបផែបតែស្ត

(Pap Test)

# Having a Pelvic Exam and Pap Test

## វិធីរៀបចំខ្លួនដើម្បីការពិនិត្យស្បូនរបៀបផែលវិក (Pelvic Exam)

- គិលានុបដ្ឋាយិកានឹងសួរអ្នកអំពីសុខភាពរបស់អ្នក។

- អ្នកនឹងចូលទៅក្នុងបន្ទប់ពិនិត្យជម្ងឺ។ អ្នកនឹងពាក់អាវក្រដាស ហើយប្រើក្រដាសមួយសន្លឹកទៀត គ្របលើខ្លួនរបស់អ្នក។

- អ្នកនឹងគេងនៅលើតុ ដោយមានក្រដាសគ្របជើងនិងពោះ អ្នកត្រូវដាក់ជង្គង់ទាំងពីរទៅក្រៅ ហើយសិកជើងទៅក្នុងប្រដាប់ដាក់ជើងហៅថាស្នៀរ៉ាប់ (stirrups)។

## ការពិនិត្យស្បូន

- គិលានុបដ្ឋាយិកាឬគ្រូពេទ្យ ពិនិត្យមើលក្នុងរន្ធយោនី ដើម្បីរកមើលរោគសញ្ញាដែលធ្វើឲ្យមានដំបៅ ឬបញ្ហាផ្សេងៗ។

- គិលានុបដ្ឋាយិកាឬគ្រូពេទ្យនឹងសិកប្រដាប់ម៉្យាង មានរៀងដូចចំពុះទា ដែលធ្វើពីកៅស៊ូឬដែក ចូលទៅក្នុងរន្ធយោនី។

- នៅពេលពិនិត្យស្បូនរបៀបផែបតែស្ត គិលានុបដ្ឋាយិកាឬគ្រូពេទ្យនឹងប្រើបន្ទះស្តើងតូចមួយកោសសើរៗ ដើម្បីយកកោសិកាពីកស្បូន (ទ្វាមាសបើកទៅក្នុងស្បូន)។ មន្ទីរពិសោធន៍នឹងពិនិត្យកោសិកាទាំងនេះ ដើម្បីរកមើលជម្ងឺមហារីក ឬបញ្ហាផ្សេងៗ។ ប្រសិនបើរកឃើញមហារីកនៅពេលដែលទើបតែ កកើតឡើងថ្មីៗ វាងាយស្រួលក្នុងការព្យាបាលឲ្យបានជាសះស្បើយ។





- បន្ទាប់ពីធ្វើការពិនិត្យស្បូនរបៀបផែបតែស្ត គិលានុបដ្ឋាយិកា ឬគ្រូពេទ្យ នឹងពិនិត្យបំពង់ស្បូន ដៃស្បូន ហើយនិងស្បូន ដោយប្រើម្រាមដៃពីរ ដែលមានពាក់ស្រោម សកចូលទៅក្នុងរន្ធយោនី។ ឯដៃម្ខាងទៀត ស្ទាបពីក្រៅដើម្បីរកដុំ ឬភាពទន់ហើម វិធីនេះប្រើពេលតែពីរឬបីនាទីប៉ុណ្ណោះ។

- នៅពេលពិនិត្យរួចហើយ អ្នកអាចស្លៀកពាក់សំលៀកបំពាក់របស់អ្នកវិញ។

- ចូរចាំថា៖ បើមានសំណួរអ្វី ត្រូវសួរមុនពេលដែល គិលានុបដ្ឋាយិកា ឬគ្រូពេទ្យចាកចេញពីបន្ទប់។

លទ្ធផលនៃការពិនិត្យស្បូនរបៀបផែបតែស្តភាគច្រើនគឺប្រក្រតី។

គ្រូពេទ្យឬមន្ទីរពិនិត្យជម្ងឺនឹងទាក់ទងអ្នក បើលទ្ធផលនៃការពិនិត្យស្បូនរបស់អ្នកមានភាពមិនប្រក្រតី។

ចូរទូរសព្ទទៅគ្រូពេទ្យប្រចាំគ្រួសារ ឬមន្ទីរពិនិត្យរោគនៅតាមតំបន់របស់អ្នក នៅក្នុងថ្ងៃនេះ ដើម្បីធ្វើការណាត់សំរាប់ពិនិត្យស្បូនរបៀបផែបតែស្ត។

ការណាត់ពិនិត្យស្បូនរបៀបផែបតែស្តរបស់ខ្ញុំ:

ថ្ងៃខែ: ____________________

ពេលវេលា: ____________________

ទីកន្លែង: ____________________

លេខទូរសព្ទ: ____________________

## Getting Ready for the Pelvic Exam

- A nurse will ask you about your health.
- You will go into the exam room. You will have a paper gown to put on and a sheet to cover you.
- You will lie down on the table with a sheet over your legs and stomach. You will let your knees fall to the side and put your feet in holders called stirrups.

## Having the Exam

- The nurse or doctor will look at your vaginal area to see if you have any signs of infection or other problems.
- The nurse or doctor will slide a thin piece of plastic or metal that looks like a duck bill into your vagina to check inside.
- During the Pap test, the nurse or doctor will use a small brush to take a few cells from your cervix (the opening to the womb). A lab will check these cells for cancer or other problems. If cancer is found early, it is easier to cure.





- After the Pap test, the nurse or doctor will check your tubes, ovaries, and uterus (womb) by putting two gloved fingers inside your vagina. With her other hand, she will feel from the outside for any lumps or tenderness. This takes only a few minutes.
- The exam is over and you can get dressed.
- Be sure to ask any questions before the nurse or doctor leaves the room.

## Most Pap test results are normal.

## The doctor or clinic will contact you if yours is not.

**Call your family doctor or local medical clinic TODAY for a Pap test appointment.**

*My appointment for a Pap test:*

Date: ______________________________

Time: ______________________________

Place: ______________________________

Telephone: ___________________________



Adapted and translated from NIH Publication No. 99-3416.
Funding for development of this pamphlet: NCI AANCART CA86322.
This booklet is not currently available for general distribution.

FRED HUTCHINSON CANCER RESEARCH CENTER

HARBORVIEW MEDICAL CENTER

AANCART